# ប្រជុំបណ្តាញស្ត្រីជនបទ

បណ្តាញស្ត្រីគឺជា បណ្តាញជំនាញស្ត្រីនៅតាមជនបទ ដែលមានការដឹកនាំដោយស្ត្រីគឺមានការទទួលស្គាល់យ៉ាងខ្លាំងពីស្ថាប័នខាងក្រៅ និងស្ថាប័នដែលពាក់ព័ន្ធ ។ នៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០០៨ នៅសាលប្រជុំទីផ្សារកសិផលធម្មជាតិ មានរៀបចំប្រជុំបណ្តាញស្ត្រីជនបទ ដោយមានមានស្ត្រីបង្គោលតាមខេត្តនីមួយៗ ចំនួន ១២ នាក់ ចូលរួម និងសម្របសម្រួលដោយកញ្ញា **គង់ សុខឈាន់**។ ការប្រជុំនេះធ្វើឡើងក្នុងគោលបំណង:

- ពិភាក្សាឆ្លុះបញ្ចាំងពីសកម្មភាពការងារកន្លងមក
- ធ្វើផែនការសកម្មភាព និង ផែនការថវិកា
- រៀបចំយុទ្ធសាស្ត្រដើម្បីជ្រើសរើសស្ត្រីបង្គោលតាមខេត្ត

ឆ្លងតាមការប្រជុំនេះ លក្ខណៈវិនិច្ឆ័យមួយចំនួនត្រូវបានកំណត់ក្នុងការជ្រើសរើសស្ត្រីបង្គោលតាមមូលដ្ឋានៈ

១. មានចំណេះដឹងអាចសរសេរបាន អានបាន ស្តាប់បាន

២. មានគំនិតចង់ជួយគេ

៣. ហ៊ានលះបង់ពេលវេលា, មានពេលវេលាក្នុងការចូលរួម

៤. យល់ដឹងពីការងារស្ត្រី (សុខភាព អនាម័យ គ្រប់គ្រងផ្ទះសំបែង)

៥. ក្លាហាន

៦. ជាគ្រួសារគំរូ (គ្មានអំពើហិង្សាក្នុងគ្រួសារ)

៧. ជាស្ត្រីមានឥទ្ធិពល មានប្រសិទ្ធិភាព

នៅចុងបញ្ចប់អ្នកចូលរួមទាំងអស់មានភាពសប្បាយរីករាយ ដោយដឹងថាមានការទទួលស្គាល់យ៉ាងខ្លាំងពីស្ថាប័នខាងក្រៅ ចំពោះបណ្តាញស្ត្រី ហើយមើលឃើញថានៅពេលអនាគត បណ្តាញស្ត្រីនឹងមានភាពឯករាជ្យ អាយរកលុយចាយបានដោយខ្លួនឯង ហើយមានអ្នកធ្វើការនៅតាមមូលដ្ឋានទៀតផង ។ នៅពេលត្រឡប់ទៅវិញអ្នក ទាំងអស់នឹងធ្វើការរៀបចំជ្រើសរើសស្ត្រីបង្គោលនៅតាមមូលដ្ឋាននៅតាមខេត្តរៀងៗខ្លួន ដើម្បីជួយធ្វើការគាំទ្រដល់ស្ត្រីតាមមូលដ្ឋាន ។